# សម្ភាសន៍ជាមួយឈ្មោះ ខឿ ងឹក់ ភេទស្រី អាយុ៨៩ឆ្នាំ

មុខងារជនជាតិខ្មែរក្រហម «ប្រជាជនធ្វើការនៅកងចល័ត »

រស់នៅភូមិតាប៉ែន ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន ចាន ប្រុញ និង ឡា យុំ

០១:០៨:៤៨

៣៣ទំព័រ

ប៊ុនថន : ដំបូងខ្ញុំសួរឈ្មោះមីង មីងឈ្មោះអីដែរ?

ងឹក់ : ឈ្មោះ ខឿ ងឹក់ ។

ប៊ុនថន : ខឿ ងឹក់ មីងអាយុប៉ុន្មានហើយសព្វថ្ងៃ?

ងឹក់ : ៨៩ហើយ ។

ប៊ុនថន : ៨៩ឆ្នាំ?

ងឹក់ : ចា៎!

ប៊ុនថន : មីងស្រុកកំណើតនៅភូមិឃុំអីដែរ?

ងឹក់ : នៅភូមិនេះឯងស្រុកកំណើត ។

ប៊ុនថន : នៅភូមិតាប៉ែន ឃុំព្រះនេត្រព្រះ?

ងឹក់ : ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

ប៊ុនថន : មីងមានបងប្អូនប៉ុន្មាននាក់?

ងឹក់ : បងប្អូនបួននាក់ ។

ប៊ុនថន : ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ងឹក់ : ស្រីពីរទាំងខ្ញុំ ប្រុសពីរ ។

ប៊ុនថន : នៅរស់ជុំគ្នាទេតើហ្អឹមីង?

ងឹក់ : គេនៅបានប្រពន្ធបែកបាក់អស់ហើយនៅតែខ្ញុំទេ នៅភូមិនេះមានតែខ្ញុំទេ ។

ប៊ុនថន : បួននាក់ស្រីទាំងអស់?

ងឹក់ : ស្រីពីរប្រុសពីរ ។

ប៊ុនថន ៖ បែកទៅនៅភូមិណាខ្លះមីង?

ង៉ីក់ ៖ មួយបានប្រពន្ធនៅពាម អាមួយនោះនៅនេះ មួយទៀតនៅសៀមរាប ។

ប៊ុនថន ៖ នៅនេះនៅតែមីងទេ?

ង៉ីក់ ៖ ចាស ។

ប៊ុនថន ៖ ចុះឪពុកម្ដាយនៅរស់ទេមីង?

ង៉ីក់ ៖ ឪពុកម្ដាយខ្ញុំស្លាប់អស់ហើយ ។

ប៊ុនថន ៖ ស្លាប់ជំនាន់ណាដែរ?

ង៉ីក់ ៖ បើម៉ែនោះស្លាប់កាលសម័យនោះ សម័យអាពត ។

ប៊ុនថន ៖ គាត់ស្លាប់ដោយសារអី?

ង៉ីក់ ៖ ខ្ញុំមិនបាននៅគ្រប់គ្រង់ទេ មិនបានថែរក្សាទេ ហើយខ្ញុំចាប់ធំភ្លាមគេចុះឈ្មោះយកទៅភ្លាម ។

ប៊ុនថន ៖ ចុះឪពុក?

ង៉ីក់ ៖ ឪពុកស្លាប់ដែរ ។

ប៊ុនថន ៖ ឪពុកស្លាប់ជំនាន់ណា?

ង៉ីក់ ៖ គាត់ស្លាប់ពេលវៀតណាមចូលមកហើយ ស្លាប់ក្រោយ ។

ប៊ុនថន ៖ ចុះអ្នកមីងបានរៀនសូត្រទេ?

ង៉ីក់ ៖ អត់ទេ ។

ឡា យុំ ៖ ពីដើមមានសាលាទេនៅត្រង់នេះ ទើបតែមានឥឡូវទេ?

ង៉ីក់ ៖ អត់មានទេ ។

ប៊ុនថន ៖ ចុះមីងអត់ទៅរៀនចឹងនៅជាមួយឪពុកម្ដាយរហូត?

ង៉ីក់ ៖ ខ្ញុំហ្នឹង?

ប៊ុនថន ៖ បាទ!

ង៉ីក់ ៖ ខ្ញុំមិនដែលបាននៅជាមួយគាត់ទេ មិនដែលបានថែរក្សាគាត់ទេ ។

ប៊ុនថន ៖ ពីក្មេងណាសមីង?

ង៉ីក់ ៖ ចាស ពីក្មេង ។

ប៊ុនថន ៖ មីងទៅណា អត់នៅជាមួយគាត់មីងទៅណា?

ងីក់ : ខ្ញុំនៅជាមួយបងប្អូន ឪពុកខ្ញុំក៏ប្អូនខ្ញុំនៅខែវស្សាទើបតែខ្ញុំបានប្ដីហើយ មុនហ្នឹងប្អូនថៃវក្សាពុក ។

ប៊ុនថន : ទៅនៅជាមួយបងប្អូននៅឯណាវិញ នៅភូមិនេះឬភូមិណា?

ងីក់ : នៅភូមិស្រម៉ោច ។

ប៊ុនថន : ភូមិស្រម៉ោច?

ងីក់ : ចាស ។

ប៊ុនថន : គាត់ត្រូវជាស្អីជាមួយអ្នកមីង?

ងីក់ : ត្រូវជីដូនមួយ ។

ប៊ុនថន : ចឹងមីងទៅនៅជាមួយគាត់រហូតដល់ខ្មែរក្រហមចូលមក?

ងីក់ : ទេ ពេលចាប់ផ្ដើមខ្ញុំនៅជាមួយម៉ែឪខ្ញុំ ដល់អាពេលខ្មែរក្រហមចូលមកគេកត់ឈ្មោះខ្ញុំឪក៏ទៅចូលម៉ែឪខ្ញុំទៀត ។

ប៊ុនថន : ចុះឈ្មោះទៅណា?

ងីក់ : ចុះដើរទៅខាង ដើរគ្រប់ច្រកទៅអាងត្រពាំងថ្ម ស្អីគេហៅភ្នំកោះរំាល់ ។

ប៊ុនថន : អ្នកណាអ្នកចុះឈ្មោះមីង?

ងីក់ : មិនដឹងបើមិនដែលស្គាល់ផងតែគ្រាន់តែគេហៅទៅ ។

ប៊ុនថន : ចុះគេមានជម្លៀសមីងទៅណាទេ កាលពីដំបូងណាស?

ងីក់ : ជម្លៀសពីភូមិ?

ប៊ុនថន : បាទ!

ងីក់ : ទៅនៅស្រែះ ។

ប៊ុនថន : ទៅនៅស្រែះ?

ងីក់ : ចាស ស្រែះ ។

ប៊ុនថន : ទៅនៅស្រែះ ជម្លៀសមីងពីណាទៅពីស្រមោចឬពីតាប៉ែន?

ងីក់ : ពីតាប៉ែនទៅនៅស្រែះកើតដល់ចេញពីស្រែះទៅនៅប៉ោយសំរោង ។

ប៊ុនថន : បាទ! ទៅនៅស្រែះយូរដែរមីងទៅនៅស្រែះ ។

ងីក់ : មិនសូវយូរទេ នៅប៉ោយសំរោងបានយូរក្រែលដែរម៉ោចប់វៀតណាមចូល ។

ប៊ុនថន : ទៅទាំងគ្រួសារម៉ងហ្អីមីង?

ងីក់ : ទៅទាំងអស់ម៉ាភូមិ ។

ប៊ុនថន ៖ ភូមិណាខ្លះមីងជម្លៀសទៅស្រះហ្នឹង?

ងឹក ៖ មិនដឹងភូមិណាខ្ញុំដឹងតែភូមិតាប៉ែន ។

ឡា យ៉ុំ ៖ និយាយទៅជម្លៀសដែរ តែប្ដូរកន្លែងអត់ឲ្យនៅកន្លែងចាស់ទេ?

ងឹក ៖ ចាស ដូរគ្នា ។

ឡា យ៉ុំ ៖ ជួនកាលផ្ទះសំបែងនៅក្នុងភូមិអត់ឲ្យនៅទេទៅនៅក្នុងព្រៃភ្លាវព្រៃធ្វើផ្ទះនៅ ។

ងឹក ៖ ចាំ!

ឡា យ៉ុំ ៖ គេហៅទៅដំបូងហ្នឹងគេប្រាប់ថាទៅធ្វើអី ហើយមានចូលរួមជាមួយចលនាដែរអត់?

ងឹក ៖ ខ្ញុំហ្នឹង?

ឡា យ៉ុំ ៖ បាទ!

ងឹក ៖ គេហៅទៅឲ្យលើកដីតែម្ដង ។

ឡា យ៉ុំ ៖ ធ្វើការរួម?

ងឹក ៖ ចាស ។

ឡា យ៉ុំ ៖ ហូបរួម?

ងឹក ៖ ហូបរួម ទៅលើកដីតែម្ដង ។

ឡា យ៉ុំ ៖ ចាំឆ្នាំដែរអត់ទេ?

ងឹក ៖ អត់ចាំទេ មិនបានគិតមិនបានអីមិនដែលចាំទេ ។

ឡា យ៉ុំ ៖ លើកដីហ្នឹងលើកទំនប់ប្រឡាយហ្នឹងហ្អី?

ងឹក ៖ លើកទំនប់ មានអាធំបើទៅខាងត្រពាំងថ្មលើកតែអាង លើកទំនប់ធំ ។

ឡា យ៉ុំ ៖ ចុះកងវ៉ាទៅធ្វើអី?

ងឹក ៖ កងវ៉ាទៅបេះដង្កូវថ្នាំ កប្បាស ។

ឡា យ៉ុំ ៖ ទៅបេះដង្កូវ?

ងឹក ៖ បេះដង្កូវកប្បាស ។

ឡា យ៉ុំ ៖ គេដាំកប្បាសនៅហ្នឹង?

ងឹក ៖ ចាស ។

ឡា យ៉ុំ ៖ ហើយពេលចាប់ផ្ដើមដំបូងយ៉ាងម៉េចដែរហូបចុក ហើយអារម្មណ៍យ៉ាងម៉េចដែរពេល យើងចាប់ផ្ដើមធ្វើការងាររួមចឹង?

ងឹក ៖ ហូបម៉ាថ្ងៃពីរពេល បាយវាល់ចែកគ្នា ។

ឡា យុំ : យើងធ្លាប់នៅផ្ទះយើងចឹងរបៀបរស់នៅផ្សេងនឹកឃើញទេនឹកឃើញអារម្មណ៍ហ្នឹងដំបូង?

ងឹក់ : ហូបអត់ឃ្លាន ដួនកាលទៅបានហូបឆ្អែតទៅដួនកាលអត់ទៅបានម្នាក់ម៉ាវែកៗទៅ ។

ឡា យុំ : ហើយចុះនឹកឃើញថាកាលនោះគេធ្វើរបៀបហ្នឹងឲ្យយើងផ្លាស់ប្តូររបៀបរស់នៅគិតថាវាល្អឬអាក្រក់?

ងឹក់ : អត់ល្អទេ ។

ឡា យុំ : ចុះយើងរស់នៅខ្លួនឯងខ្លះអីយើងរកខ្លួនយើងហើយអាគេជួយអត់ឃើញខុសគ្នាទេ?

ងឹក់ : ខ្ញុំមិនដែលហ៊ានដើរលួចគេទេខ្លាចគេណាស់មិនដែលហ៊ានដើរលួចដើរឆក់កណ្តៀតបងប្អូនណាទេ ។

ឡា យុំ : ចុះនឹកឃើញថាកាលមុនមាន លន់ នល់ នៅមានអាមេរិកអីនៅក្រោយមកមានខ្មែរក្រហមឈ្មោះអីចឹងណាសយើងអត់នឹកឃើញថាសិទ្ធិសេរីភាព ជីវភាពរស់នៅល្អអីល្អឬអាក្រក់ជាងមុនទេហ្អី?

ងឹក់ : ជាប់សម័យនេះហ្អី?

ឡា យុំ : កាល លន់ នល់ ណាសព្រោះកាល លន់ នល់ គាត់ធំដែរហើយ កាលនោះវាមានសង្គ្រាមមិនអីចឹងដល់ពេលខ្មែរក្រហមគេឈ្មោះទៅសន្តិភាពហើយអាហ្នឹងណាស ។ លែងបាញ់លែងសង្គ្រាមហើយតែវាទៅជាម្យ៉ាងទៀតការរស់នៅ ។

ងឹក់ : ហ្នឹងហើយប្រើអំពើហឹង្សា ។

ឡា យុំ : គេប្រើម៉េចខ្លះ?

ងឹក់ : ប្រើ មានអ្នកលួច ឆក់ ប្លន់របស់គេ គេយកមកវ៉ៃចោលចឹងទៅ ហើយមិនដែលទៅលួចអីរបស់គេទេ ដូចជាចេក ដំឡូង ត្រពាំងអីខ្ញុំថាគេមិនឲ្យគេលួចទេខ្លាច ។

ឡា យុំ : ភាគីដែលគេយកមកប្រជុំវែកញែករកខុសរកត្រូវអីឲ្យអ្នកហ្នឹងសារភាពទេមុនពេលគេយកទៅវ៉ៃចោល?

ងឹក់ : អត់មានទេ គេស្រាប់តែយប់ឡើងគេហៅគ្នាទៅអត់ ។

ឡា យុំ : គ្រាន់តែឮតែមិនបានឃើញផ្ទាល់ភ្នែកទេ?

ងឹក់ : ទេមិនបានឃើញទេបានតែឮថាអ្នកនេះអ្នកនោះងាប់

ឡា យុំ : ប៉ុន្តែបាត់អ្នកហ្នឹងមែន?

ងឹក់ : ដោយសារលួចរបស់គេ

ឡា យុំ : អ្នកណាអ្នកយកទៅ?

ង៉ីក់ ៖ ប្រធានៗគេ នៅខាងនិរតី ។

ឡា យុំ ៖ ចាំឈ្មោះទេ?

ង៉ីក់ ៖ អត់ចាំទេ ។

ឡា យុំ ៖ ជាស៊ីវិលឬក៏មានកាំភ្លើងកាន់ដែរ?

ង៉ីក់ ៖ មាន ។

ឡា យុំ ៖ បែបឈ្លបហើយ?

ង៉ីក់ ៖ ចាស ឈ្លបគេ សេនាជន ។

ឡា យុំ ៖ ហើយអ្នកភូមិយើងដែរទេ?

ង៉ីក់ ៖ អត់មានទេ ។

ឡា យុំ ៖ ឈ្លបហ្នឹងមកពីផ្សេងហ្អី?

ង៉ីក់ ៖ មកពីខាងគេផ្សេង ។

ឡា យុំ ៖ ហើយម៉េចដែរសំដីសំដៅចរិកឬកពាអីមើលទៅប្រៀបធៀបជាមួយអ្នកស្រុកភូមិយើង ដែលធ្លាប់រស់នៅជាមួយគ្នា និយាយស្តាប់គ្នាឬយ៉ាងម៉េច?

ង៉ីក់ ៖ គេនិយាយមិនសូវស្តាប់គ្នាទេ...

ឡា យុំ ៖ អត់តមាត់បានទេ?

ង៉ីក់ ៖ អត់ហ៊ានទេ អត់ហ៊ានតមាត់ទេ ខ្ញុំខ្លាចគេឡើងដល់សម័យវៀតណាមចូលបានខ្ញុំរកពុកខ្ញុំ បងប្អូនថាខ្ញុំស្លាប់ហើយ ។

ឡា យុំ ៖ ខ្លាចអីគេ?

ង៉ីក់ ៖ ខ្លាចគេយកទៅវៃចោល ។

ឡា យុំ ៖ ធំជាងគេហើយហ្អី?

ង៉ីក់ ៖ ខ្លាចជាងគេមិនដែលហ៊ានសុំគេមកទេ ខ្លាចងាប់ខ្លួនដែរចេះតែតស៊ូ ។

ប៊ុនថន ៖ ចុះមីងចេញពីភូមិដំបូងទៅធ្វើការងារអីគេ?

ង៉ីក់ ៖ ចេញពី ជម្រៀសហើយហ្នឹង?

ប៊ុនថន ៖ បាទ ចេញមីងចូលកងហើយគេបញ្ជូនឲ្យទៅធ្វើការដំបូងមីងទៅណាវិញ?

ង៉ីក់ ៖ មុនដំបូងលើកទំនប់ភ្នំកំបោរ ។

ប៊ុនថន ៖ ទំនប់ហ្នឹងធំទេមីង?

ង៉ីក់ ៖ ធំណាស់ ។

ប៊ុនថន ៖ ប្រវែងប៉ុន្មានមីងមានដឹងទេ?

ងឹក ៖ មិនដឹងប៉ុន្មាន ទំនប់គេធំណាស់ស្ពានរនុះបាញ់ស្ពានអី ទំនប់កំពោរ ។

ប៊ុនថន ៖ កាលនោះកងមីងនៅជាមួយអ្នកណាមីង?

ងឹក ៖ នៅជាមួយប្រធាន ប្រធានកុមារគេតែឥឡូវងាប់អស់ហើយ ងាប់នៅសម័យនេះ ។

ប៊ុនថន ៖ មានចាំឈ្មោះគាត់ទេមីង?

ងឹក ៖ ចាំ ។

ប៊ុនថន ៖ ឈ្មោះអីគេវិញមីង?

ងឹក ៖ ឈ្មោះ ឃឿន ។

ប៊ុនថន ៖ គាត់នៅឯណាវិញ?

ងឹក ៖ គាត់នៅនេះឯងតែគាត់ស្លាប់បាត់ហើយ ។

ប៊ុនថន ៖ អីចឹងមីងនៅកងកុមារទេ?

ងឹក ៖ ខ្ញុំនៅកងកុមារគេដាក់កុមារ ។

ប៊ុនថន ៖ ប៉ុន្មាននាក់ម៉ាកងមីង?

ងឹក ៖ ម៉ាក្រុមៗវាមានដប់នាក់ ដល់ម៉ាកងវរៈគេប៉ុន្មាននាក់ទេ?

ប៊ុនថន ៖ បីរយនាក់ ។

ងឹក ៖ ចាស បីរយនាក់ ។

ប៊ុនថន ៖ អីចឹង ឃឿន ហ្នឹងប្រធានកងវរៈ?

ងឹក ៖ ប្រធានកងកុមារប្រធានក្រុមខ្ញុំ ។

ប៊ុនថន ៖ តែដប់នាក់ទេ?

ងឹក ៖ ចាំ!

ប៊ុនថន ៖ កាលនោះមីងធ្វើការអីខ្លះមីង?

ងឹក ៖ លើកទំនប់ ផុតពីទំនប់ទៅគេបញ្ជូនឲ្យទៅបេះដផ្កាវកប្បាសនៅភ្នំកងវ៉ា ។

ប៊ុនថន ៖ លើកទំនប់ហ្នឹងមានវាស់កំណត់ឲ្យលើកទេមីង?

ងឹក ៖ គេកំណត់ណាស់ ។

ប៊ុនថន ៖ ម៉ាថ្ងៃធ្វើការ...

ងឹក ៖ ម្នាក់ពីរម៉ែត្រគីប ។

ប៊ុនថន ៖ កុមារហ្នឹងពីរម៉ែត្រគីបដែរ?

នឹក់ ៖ ពីរម៉ែត្រគីប លើកទាំងយប់ទាំងថ្ងៃ ។

ឡា យុំ ៖ ម៉ាថ្ងៃម៉ាយប់ហ្នឹង?

នឹក់ ៖ ចា៎!យប់ពីរម៉ែត្រគីប ថ្ងៃពីរម៉ែត្រគីប ។

ប៊ុនថន ៖ ចឹងម៉ាថ្ងៃ៤ម៉ែត្រគីប?

នឹក់ ៖ ចាស ។

ប៊ុនថន ៖ ចឹងមីងធ្វើហើយទេដូចថាច្រើនចំនួនចឹង?

នឹក់ ៖ ខ្លាចគេនោះចេះតែខំឲ្យរួចទៅ ។

ប៊ុនថន ៖ ចុះបើធ្វើអត់រួចមីង?

នឹក់ ៖ ធ្វើអត់រួចគេវ៉ៃគេសម្លាប់យើង គេថាឲ្យយើងទៅ ។

ប៊ុនថន ៖ ថាសម្លាប់អីចឹងមាន ចុះនៅកងមីងមានដូចថាគេធ្វើទារុណកម្មធ្វើអីទេ?

នឹក់ ៖ កុមារចឹងមិនសូវធ្វើបាបទេ បើខាងភូមិយុវជន នារីបានគេធ្វើបាប វ៉ៃយកណ្តាល ។

ប៊ុនថន ៖ ធ្វើបាបម៉េចខ្លះទៅមីង?

នឹក់ ៖ គេធ្វើបាបយកទៅសំលាប់ចោល វ៉ៃចោលហ្នឹងណាសថាយើងខុសសីលធម៌ ។

ប៊ុនថន ៖ ធ្លាប់មានទេមីង ។

នឹក់ ៖ មាន ។

ប៊ុនថន ៖ មាននៅចាំទេ ពីណា?

នឹក់ ៖ តែខ្ញុំមិនសូវស្គាល់ទេមិនសូវចាំទេ ផ្ទះគេនៅជិតៗគេប្រាប់ថាយកអ្នកនេះអ្នកនោះទៅវ៉ៃ
វាងាប់ហើយ ។ ខ្ញុំមិនសូវហ៊ាននិយាយផងកាលនោះ តែស្រលាញ់គ្នាក៏មិនឲ្យស្រលាញ់
គ្នា ចាប់បានវាវ៉ៃៗឲ្យឃើញនឹងមុខ ។

ប៊ុនថន ៖ ចុះការងារអីពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានមីង?

នឹក់ ៖ ម៉ោង១២ហូបបាយ ។

ប៊ុនថន ៖ ពេលព្រឹកចាប់ពីម៉ោងប៉ុន្មាន?

នឹក់ ៖ ចាប់ពីម៉ោង៦ ។

ប៊ុនថន ៖ ៦ព្រឹក?

នឹក់ ៖ ចា៎!

ប៊ុនថន ៖ ម៉ោង១២ហូបបាយ?

នឹក់ ៖ ចា៎!

ប៊ុនថន : ចុះពេលល្ងាចមីងចុះទៅម៉ោងប៉ុន្មាន?

ងិក : ល្ងាចដួនកាលពីម៉ោង៥ ។

ប៊ុនថន : ចូលម៉ោងប៉ុន្មាន?

ងិក : ចូល...

ប៊ុនថន : ចូលធ្វើការដល់ពេលល្ងាចណាស?

ងិក : ល្ងាចហូបតែបាយរួចចាប់ផ្ដើម ។

ប៊ុនថន : បាទ!ចុះដូចរបបអាហារអីយ៉ាងម៉េចដែរមីងម៉ាថ្ងៃប៉ុន្មានពេល?

ងិក : ម៉ាថ្ងៃពីរពេលហ្នឹងឯង ។

ឡា យុំ : បាយឬបបរ?

ប៊ុនថន : បាយ ។

ងិក : អាហ្នឹងដំបូងៗឬរហូត?

ប៊ុនថន : ខ្ញុំនៅខាងចល័តកុមារណាសគេអត់សូវឲ្យហូបបបរទេ គេឲ្យហូបតែបាយ បាយគេវាល់ចាន ។

ងិក : ខ្ញុំនៅខាងចល័តកុមារណាសគេអត់សូវឲ្យហូបបបរទេ គេឲ្យហូបតែបាយ បាយគេវាល់ចាន ។

ប៊ុនថន : ប៉ុន្មានមីង?

ងិក : ម្នាក់ម៉ាចានៗ ។

ប៊ុនថន : ចានប៉ុណ្ណា?

ងិក : អាចានប៉ែតយើងហ្នឹង ។

ប៊ុនថន : គេហៅចានទាបយើងហ្នឹងហ្អី?

ងិក : ហ្នឹងហើយ ។

ប៊ុនថន : ឆ្អែតទេអ្នកមីងពីរពេលចឹង?

ងិក : ហូបឆ្អែតមិនមិនឆ្អែតក៏មិនដឹងធ្វើម៉េចបើគេឲ្យតែប៉ុណ្ណឹង ។

ប៊ុនថន : ប៉ុន្តែដូចមីងហូបតែប៉ុណ្ណឹងហើយធ្វើការ៨ម៉ែត្រគីបចឹងសំរាប់មីងផ្ទាល់ឆ្អែតដែរ?

ងិក : ថាមិនឆ្អែតក៏មិនថាបើគេឲ្យហូបតែប៉ុណ្ណឹង ថាមិនឆ្អែតទៅរកអីណាបានទៀត ។

ប៊ុនថន : ចុះមីងនៅក្នុងកងកុមារមីងមានអ្នកជម្លៀសថ្មីៗមកជាមួយមីងទៀតទេ?

ងិក : អត់មានអ្នកណាមកជាមួយទេច្រើនតែអ្នកថ្មី ។

ប៊ុនថន :	មានអ្នកមកពីភ្នំពេញមកពីអីទេ?

នឹក :	មានមកពីខាងណុងឯង តែងាប់អស់ហើយ ។ ខ្លះដាច់ពោះបាយងាប់អស់ទៅ ។

ប៊ុនថន :	អ្នកថ្មីហ្នឹងស្លាប់ដោយសារអីដែរមីង?

នឹក :	ស្លាប់ដោយសារដាច់ពោះ ឈឺទៅក៏ងាប់ទៅ ។

ប៊ុនថន :	ហើយការងារអ្នកដែលជម្លៀសមកថ្មីៗ ដែលមកធ្វើការជាមួយមីងធ្វើបានទេដូចអត់ដែលធ្លាប់ធ្វើការធ្ងន់ៗចឹងណាស?

នឹក :	ដល់គេដាក់ទិសចឹងចេះតែខំ ខ្លាចគេចេះតែខំទៅ ។

ឡា យុំ :	ហើយខ្លាចៗតែរឿងតូចតាចខ្លាចស្លាប់ហ្នឹង?

នឹក :	ចាស ខ្លាចតែស្លាប់ ឈឺល្មមៗអាឡៀតែសំរាកគេថាឯងឈឺសតិអារម្មណ៍ ឈឺពុត ទៅទាំងនោះឯង ។

ប៊ុនថន :	ចុះគេដែលប្រជុំដែលអីទេមីងកងក្មេងៗ ?

នឹក :	ប្រជុំ ។

ប៊ុនថន :	ប្រជុំជាមួយពីណាមីង?

នឹក :	ប្រជុំមកពីណាៗច្រើនណាស់ ប្រជុំនៅអាងត្រពាំងថ្មកន្លែងគេប្រជុំច្រើនណាស់ ។

ប៊ុនថន :	អ្នកមីងធ្វើនៅកំបោរស្រេះហ្នឹងយូរទេមីង?

នឹក :	ចំនួនម៉ាខែ ។

ប៊ុនថន :	ហើយបានដូរទៅកងវ៉ាវិញ?

នឹក :	កងវ៉ា ។

ប៊ុនថន :	ដូរហ្នឹងទៅទាំងអស់ម៉ងហ្នឹទាំងកងវរៈហ្នឹង?

នឹក :	ទៅម៉ាកងកុមារទៅទាំងអស់ហ្នឹង ដល់ពេលខ្ញុំទៅអាងត្រពាំងថ្មខ្ញុំនៅរហូតទាល់តែសម័យយក្សណោមចូលបានចេញមមក ។

ប៊ុនថន :	ទៅចំការកប្បាសហ្នឹងរៀបរាប់ថាធ្វើអីខ្លះមីង?

នឹក :	បេះដង្កូវកប្បាស បេះដង្កូវកប្បាសឲ្យគេ ។

ឡា យុំ :	បែបស្រាលការងារហ្នឹងតាមមើល

នឹក :	ចាស ស្រាល ។

ឡា យុំ :	ការងារល្អជាងគេហ្ន៎?

នឹក :	ចាស ។

ប៊ុនថន ៖ ប្រធានកងឈ្មោះ ឃឿន ដដែល?

ងឹក់ ៖ ឃឿន ប្រធានកង ឃឿន ។

ប៊ុនថន ៖ មិនមែនប្រធានវរៈទេហ្អីមីង?

ងឹក់ ៖ ទេ ប្រធានវរៈគេផ្សេង ។

ឡាញ យ៉ុំ ៖ ប្រធានកងប្រធានក្រុមគេអត់ធ្វើការទេហ្អីគេគ្រាន់តែឈរបញ្ជា?

ងឹក់ ៖ ធ្វើដូចគ្នា ។

ឡាញ យ៉ុំ ៖ ធ្វើដែរទេ?

ងឹក់ ៖ ចាស ធ្វើ ។

ឡាញ យ៉ុំ ៖ អត់មានឈរបញ្ជាទេ?

ងឹក់ ៖ អត់ទេធ្វើដូចគ្នា ។

ឡាញ យ៉ុំ ៖ ប៉ុន្តែហូបៗជាមួយយើងដែរអត់ទេ?

ងឹក់ ៖ ហូបជាមួយគ្នា បើកបាយទៅហូបជាមួយគ្នា ។

ឡាញ យ៉ុំ ៖ អត់មានលើលខ្វះ លើសត្រីអាំងមួយអីទេ?

ងឹក់ ៖ អត់ទេ បើរឿងម្ហូបអត់មានអីហូបទេប៉ះណាប្រហុកអាំបិល ។

ឡាញ យ៉ុំ ៖ ដូចគ្នា?

ងឹក់ ៖ ចា៎!អំបិលដូចគ្នា ។

ឡាញ យ៉ុំ ៖ ទោះយ៉ាងណាគ្រាន់ជាងយើងដែរ ។

ងឹក់ ៖ ប៉ះណាទៅទឹកប្រហុក ទឹកប្រហុករាវប្រោកមិនដែលមានម្ជូរ មានបីចេងអីទេ ។

ឡាញ យ៉ុំ ៖ សម្លរម្ជូរអីអត់ទេហ្អី?

ងឹក់ ៖ អត់ទេ ។

ឡាញ យ៉ុំ ៖ ហើយកាលជម្លៀសទៅហ្នឹងជិះអីទៅ ដើរទៅហ្អីម៉េច?

ងឹក់ ៖ ភូមិខ្ញុំនោះ?

ឡាញ យ៉ុំ ៖ បាទ!

ងឹក់ ៖ ដើរ ។

ឡាញ យ៉ុំ ៖ ដើរតាមផ្លូវហ្នឹង?

ងឹក់ ៖ ចា៎! ដើរ មុនដំបូងទៅកំបោរដើរ ។

ឡាញ យ៉ុំ ៖ ចុះទៅកងវ៉ា?

ង៉ក់ ៖ ដល់ទៅកងវ៉ាមានឡានគេដឹក គេដឹកទៅដឹកមក បើជិតៗគេឲ្យដើរ ។

ឡា យុំ ៖ កាលនោះដូចអត់មានអារម្មណ៍ថាសប្បាយអីទេហ្អីពេលទៅថ្មីៗ ?

ង៉ក់ ៖ អត់មានអារម្មណ៍អីសប្បាយទេ ។

ឡា យុំ ៖ អត់មានរាំច្រៀងអីពេលយប់ទេ ចំរៀងកុមារ ចំរៀងបដិវត្តិអី?

ង៉ក់ ៖ មានគេបើក ម៉ាខែពីរខែគេបើកម្តង ។

ឡា យុំ ៖ បើកអី?

ង៉ក់ ៖ បើកចំរៀងកុមារគេចុះមកពីខាងណាខ្លះទេ ។

ឡា យុំ ៖ សិល្បះហ្អី?

ង៉ក់ ៖ ចាស សិល្បះ ។

ឡា យុំ ៖ គេស្លៀកពាក់ដូច ដែលឃើញកុមារគេស្លៀករាំសិល្បះសព្វថ្ងៃទេ?

ង៉ក់ ៖ អត់ដែលឃើញផង ។

ឡា យុំ ៖ អត់ដែលឃើញទេ? សិល្បះកាលនោះគេស្លៀកពាក់ម៉េច?

ង៉ក់ ៖ ស្លៀកពាក់ខ្មៅបង់ករកន្សែង ។

ឡា យុំ ៖ រចាំហើយចំរៀងវាហ្នឹងសុទ្ធតែន័យវាធ្វើការ អត់មានសប្បាយអីទេ សំរុកលើកទំនប់ ជីកប្រឡាយ ស្រលាញ់អង្គការ មានចេះចំរៀងកុមារណាមួយទេ?

ង៉ក់ ៖ ទេ ខ្ញុំមិនដែលចេះទេ ។

ឡា យុំ ៖ អត់ចាំទេហ្អី? «យើងខ្ញុំកុមារស្រលាញ់អង្គការឥតមានព្រំដែរ» អីមានចាំទេ?

ង៉ក់ ៖ ឮតែទំនុកគេច្រៀងអីចឹង តែខ្ញុំមិនដែលចេះទេ ។

ឡា យុំ ៖ ដូចគេចាក់បទ «អក្នុរាកូនៗ»អីមានដែល ឮទេ?

ង៉ក់ ៖ ឮខ្លះហើយតែមិនដែលចេះទេ ។

ឡា យុំ ៖ ទៅនៅកងវ៉ាហ្នឹងខ្លីណាស់ហ្ន៎?

ង៉ក់ ៖ ចាស ។

ឡា យុំ ៖ បានមកត្រពាំងថ្មវិញ?

ង៉ក់ ៖ បានមកត្រពាំងថ្មវិញលើកទំនប់ទៀត ។

ប៊ុនថន ៖ ម៉េចបានគេឲ្យមកត្រពាំងថ្មវិញ?

ង៉ក់ ៖ គេឲ្យមកលើកទំនប់ ដល់គេលើកទំនប់ទៅបានគេយកភូមិវ័យកណ្តាលវ័យនារីមកគេដក ភូមិខ្ញុំចេញគេឲ្យយុវជននារីលើកគេឲ្យខ្ញុំទៅរើសករគួរ ។

ប៊ុនថន : រើសអីគេ?

ងិក់ : ករគួរស្រូវ ។

ប៊ុនថន : ហ្នឹងមីងដកពីត្រពាំងថ្មមកហើយ?

ងិក់ : នៅត្រពាំងថ្មហ្នឹងហើយគេឲ្យរើស ចេញពីភូមិមកក៏ដើររើសនៅតាមស្រែគេច្រូត ស្រូវបាក់ករដើររើស ។

ប៊ុនថន : ចង់សួរទាក់ទងត្រពាំងថ្មដែលទៅដល់ត្រពាំងថ្មគេឲ្យធ្វើអី?

ងិក់ : ទៅដំបូងលើកដី ។

ប៊ុនថន : លើកដី ហើយមីងទៅដំបូងមានឃើញគេធ្វើការហើយនៅ?

ងិក់ : មាន មានគេទៅមុន នៅមុន ។

ប៊ុនថន : លើកដីហ្នឹងម៉ាងៃប៉ុន្មានមីង?

ងិក់ : វាស់ម៉ែត្រគីប?

ប៊ុនថន : ប៉ុន្មានម៉ែត្រគីបម៉ាងៃ?

ងិក់ : ម្នាក់ពីរម៉ែត្រគីប ។

ប៊ុនថន : ដូចនៅខាងកំបោរស្រះដែរ?

ងិក់ : ចាស ដូចគ្នា ។

ប៊ុនថន : ហើយការងារពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ងិក់ : មិនដែលគិតផងតែដល់ម៉ោងគេឲ្យឡើងក៏ឡើងហូបបាយទៅ ។

ប៊ុនថន : ដែលធ្វើដល់យប់ទេមីង?

ងិក់ : យប់ធ្វើ ។

ឡា យុំ : អត់មានអំពូលម៉ែត្រទេ?

ងិក់ : អត់ទេ ងងឹតឈឹង កាប់ក៏ប៉ះរើសរែកឡើងចាក់រៀងខ្លួនអត់មានភ្លើងទេ ។

ប៊ុនថន : យប់ដល់ម៉ោងប៉ុន្មានមីង?

ងិក់ : ម៉ោង ទាល់តែលើករួចពីរម៉ែត្រគីបបានគេឲ្យឡើង ។

ប៊ុនថន : ចុះបើលើកអត់ហើយ?

ងិក់ : អត់ហើយគេមិនឲ្យឡើង ។

ឡា យុំ : បើអ្នកហើយអត់ុយចាំគេទៅ?

ងិក់ : ចាស អង្គុយចាំ អត់ឲ្យជួយគ្នាទេ ។

ប៊ុនថន :	ចុះបើអ្នកធ្វើអត់ហើយ ធ្វើយប់ហើយនៅតែអត់ហើយចឹងម៉េចទៅមីង?

ងឹក់ :	នៅតស៊ូទាល់តែរួចបានគេឲ្យឡើង ចាំគ្នាទាល់តែរួច ។

ប៊ុនថន :	ដូចថាមានអ្នកខ្ជិលអី មានទេមីង?

ងឹក់ :	មានខ្លះដែរ ។

ប៊ុនថន :	គេយកទៅណាដែរអ្នកខ្ជិល?

ងឹក់ :	គេចេះតែកសាងទៅទិតខំទៅ កសាងទៅចេះតែខំប្រឹងទៅខ្លាចគេចេះតែខំទៅ ។

ប៊ុនថន :	បាទ!មានគេដកទេមីង ខ្ជិលអីគេដកពីកងយកទៅណា?

ងឹក់ :	អត់ដែលមានទេអារឿងថាដកចេញ មានតែដក មានតែសាប់ហ្នឹងហើយដកចេញ ។

ឡាា យុំ :	ដែលបានមើលកុនអីទេ ខ្ញុំធ្លាប់មើលសៀវភៅហើយមានឆ្នាំណានោះអត់ទឹកមែនទែនដូចម្នាក់ចែកទឹកឲ្យតែម៉ាដ្កិល ពីរដ្កិលអីទេយើងអត់អាចផឹកបាន ថាអត់អាចងូតបានទេបានតែផឹកហើយលប់មុខទឹកហ្នឹងប្រយ័ត្នទៀតលួចគ្នាអីចឹងណាសគេយកកុនទៅបញ្ចាំងគេបង្ហាញទឹកជ្រោះភ្នំគូលែនគេបង្ហាញទឹកសមុទ្រទឹកអីថា មីងម្នាក់នោះគាត់ក្តៅអីក្តៅថាអាឯងអត់ទឹកហើយទៅបញ្ចាំងទឹកឲ្យឯងមើលខឹងនោះខឹងដល់ហើយ ។ ឃើញមនុស្សខ្លាត់ខ្មែរចឹងម៉ងហ្អី?

ងឹក់ :	ចាស ។

ឡាា យុំ :	មានដែលសួរគ្នាទេ ហើយមុខយ៉ាងម៉េចដែរមុខអ្នកធ្វើហ្នឹងមើលទៅ មានអ្នកណាញញឹមស្រស់បស់ទេ?

ងឹក់ :	អត់មានអ្នកណាញញឹមទេ ។

ឡាា យុំ :	ហើយអត់មានគំនិតចង់តវ៉ាអីទេ?

ងឹក់ :	អត់មានទេ បើនាំគ្នាលួចរត់ក៏គេចាប់បានគេសម្លាប់ចោល ។

ឡាា យុំ :	និយាយអីចឹងយប់ឡើងដេកពួនអីយ៉ាងម៉េច?

ងឹក់ :	ដេកក្នុងខ្ទមធម្មតា ។

ឡាា យុំ :	ខ្ទមហ្នឹងអ្នកណាគេធ្វើអាហ្នឹង?

ងឹក់ :	ពួកប្រធានៗគេធ្វើ គេធ្វើដាក់គ្រែដាក់រនាបឫស្សី បើមិនរនាបឫស្សីទេឲ្យដេកនឹងដី ។

ឡាា យុំ :	ធ្វើដូចជំរុំចឹងហ្អី?

ងឹក់ :	ចាស ដេកនឹងដី ។

ឡាា យុំ :	មានកន្ទេលទេ កន្ទេលក្រហមអី?

ងិក់ : អត់មានទេ បើមានសំពត់កៅស៊ូក្រាលសំពត់កៅស៊ូ ។

ឡា យុំ : ដេកនឹងដីអស់កំលាំងហើយ ។

ងិក់ : ចាស ដេកនឹងដី មានកន្ទេលអីអត់ទេ ។ មានសំពត់កៅស៊ូក្រាលសំពត់កៅស៊ូ ។

ឡា យុំ : ហើយហូបនៅហ្នឹងដែរ?

ងិក់ : ចាស ។

ប៊ុនថន : ហូបបានប៉ុន្មានពេញដែរមីង?

ងិក់ : ម៉ាថ្ងៃពីរពេល ។

ប៊ុនថន : ហូបបបរឬក៏បាយ?

ងិក់ : បាយ មិនសូវដែលឲ្យហូបបបរទេហូបតែបាយ តែវាល់ចានចែកគ្នា ។

ប៊ុនថន : ឆ្អែតទេមីង?

ងិក់ : អារឿងរកឆ្អែតមិនឆ្អែតទេ បើបាយម៉ាចានម្នាក់ម៉េចឆ្អែត ។

ប៊ុនថន : ចុះហូបអត់ឆ្អែតចឹងមានឈឺទេមីង?

ងិក់ : ឈឺ ។

ប៊ុនថន : ឈឺអីវិញភាគច្រើន?

ងិក់ : ច្រើនតែគ្រុន គ្រុនចាញ់ ។

ប៊ុនថន : ហើយអ្នកឈឺមានថ្នាំព្យាបាលមានពេទ្យមានអីទេ?

ងិក់ : មាន ។

ប៊ុនថន : ពេទ្យនៅឯណាវិញ?

ងិក់ : ពេទ្យមិនដែលស្គាល់ផង ។

ប៊ុនថន : ពេទ្យនៅកន្លែងមីងធ្វើការម៉ងឬក៏គេយកមកណា?

ងិក់ : នៅ មានកន្លែងពេទ្យនៅហ្នឹងភ្នំកងវ៉ាមានពេទ្យគេនៅជើងភ្នំ កន្លែងពេទ្វងពេទ្យនៅជិតភ្នំ បើនៅអាងត្រពាំងថ្មពេទ្យគេនៅនោះតែម្តង ។

ប៊ុនថន : គេហៅពេទ្យអីវិញមីង?

ងិក់ : មិនដឹងគេហៅពេទ្យបើហៅតែពេទ្យ ពេទ្យគេចុះជាប់តាមកង ។

ប៊ុនថន : ចុះមីងធ្លាប់ឈឺទេ?

ងិក់ : ខ្ញុំឈឺ ។

ប៊ុនថន : ឈឺអីវិញមីង?

ង៉ិក់ :	គ្រុន ។

ប៊ុនថន :	គ្រុន ។

ង៉ិក់ :	គ្រុនក្តៅ ។

ប៊ុនថន :	ធ្ងន់ទេ?

ង៉ិក់ :	ម៉ាល្មមៗ បួនប្រាំថ្ងៃក៏បាត់ទៅ ។

ប៊ុនថន :	បាទ! ហើយមីងមានដឹងថាម៉េចបានគេសាងសង់ទំនបហ្នឹងទេ ទំនប់ត្រពាំងថ្មហ្នឹងណាស?

ង៉ិក់ :	មិនដឹងទេគេប្រាប់ឲ្យលើកទំបន់ក៏លើកទៅ ។

ប៊ុនថន :	អត់ដឹងថាម៉េចបានគេសាងសង់ទំនប់ត្រពាំងថ្មទេ?

ង៉ិក់ :	ចាស!ឲ្យលើកក៏លើកទៅ ។

ប៊ុនថន :	ធំទេទំនប់ហ្នឹង?

ង៉ិក់ :	ធំ ។

ប៊ុនថន :	ប្រហែលជាកំពស់អីប៉ុន្មានមីងចាំទេ?

ង៉ិក់ :	មិនចាំទេគេឲ្យទៅលើកចេះតែទៅលើកទៅ ។

ប៊ុនថន :	ហើយប្រវែងអីប៉ុន្មានដែរមីង?

ង៉ិក់ :	ជំរៅនោះ?

ប៊ុនថន :	បាទ ជំរៅ ។

ង៉ិក់ :	គ្មានប៉ុន្មានទេ ជំរៅពីរម៉ែត្រ គេគិតជំរៅបាតប្រឡាយពីរម៉ែត្រ ។

ប៊ុនថន :	ជីកចុះក្រោមហ្អី?

ង៉ិក់ :	ជីកចុះក្រោម ។

ប៊ុនថន :	រែកឡើងទប់ឡើងលើ ។

ង៉ិក់ :	ចាំ!

ប៊ុនថន :	ខ្ពស់ទេមីង?

ង៉ិក់ :	ខ្ពស់ណាស ។

ប៊ុនថន :	កំពស់ណាមីងបើប្រៀបធៀបជាមួយដើមឈើ?

ង៉ិក់ :	សម័យនេះខ្ញុំមិនបានឃើញមិនដឹងកំពស់ណាទេ ។

ប៊ុនថន :	កំពស់ផ្ទះមីងទេ?

ង៉ិក់ :	មិនដល់ទេ ឡើងម៉ាហត់ដែររែកឡើងម៉ាហត់ដែរ ។

ប៊ុនថន ៖ ហើយអ្នកមីងមានថាអ្នកណាអ្នកគ្រប់គ្រងធំជាងគេនៅនោះ?

ងឹក ៖ ក្នុងភូមិនេះ?

ប៊ុនថន ៖ នៅទំនប់ត្រពាំងថ្មនោះណាស?

ងឹក ៖ បើអ្នកកាន់ក្តាប់គាត់ស្លាប់អស់ហើយ ។

ប៊ុនថន ៖ ឈ្មោះអីខ្លះ?

ងឹក ៖ បើប្រធានកងខ្ញុំមានតែបងឃឿន ។

ប៊ុនថន ៖ ចុះលើគាត់ទៀត?

ងឹក ៖ លើទៀតឈ្មោះ តាវ៉ាល់ ។

ប៊ុនថន ៖ តាវ៉ាល់?

ងឹក ៖ តាមវ៉ាល់ តាម៉េាង តាសន ។

ប៊ុនថន ៖ តាសន ហើយអ្នកណាគេទៀត?

ងឹក ៖ តាសន មិនដឹងមកពីណាគេថានិរតីខ្ញុំមិនដែលស្គាល់គេផង ធ្លាប់ឃើញមុខគាត់ហៅ ។

ប៊ុនថន ៖ ចុះតួនាទីអីសនហ្នឹង?

ងឹក ៖ គាត់ប្រធានគេ ប្រធានធំគេ គាត់ក្តាប់ម៉ាអន្លក់ភាពទាំងអស់គ្នា ។

ប៊ុនថន ៖ ឈ្មោះសន ម៉ង?

ងឹក ៖ ឈ្មោះសន ។

ប៊ុនថន ៖ ចាំត្រកូលគាត់ទេ?

ងឹក ៖ អត់ដែលស្គាល់ផង គាត់មិនមែននៅស្រុកភូមិនេះផង ។

ប៊ុនថន ៖ តែគាត់ដែលចុះទៅមើលទេអ្នកមីង?

ងឹក ៖ ចុះ ចុះទៅមើលកន្លះខែ ម៉ាខែទៅមើលម្តង ។

ប៊ុនថន ៖ ចុះមានពួកបរទេសអីចុះទៅមើលនៅអាងត្រពាំងថ្មហ្នឹងទេ?

ងឹក ៖ មិនស្គាល់ទេ ។

ប៊ុនថន ៖ ដូចថាអ្នកធំៗណាស?

ងឹក ៖ អ្នកធំមានតែពួកគាត់នេះឯងខាងចុះមើលទំនប់ប្រឡាយ តែគាត់ងាប់អស់ហើយ ។

ប៊ុនថន ៖ ហើយចឹងមីងដូចថាមានអ្នកថ្មីទៅហ្នឹងច្រើនទេ ទៅប្រពាំងថ្ម?

ងឹក ៖ អ្នកថ្មីច្រើន ។

ប៊ុនថន ៖ ភាគច្រើនមកពីណាមីង?

នឹក ៖ ភាគច្រើនមកពីខាងកំពង់ចាម កំពង់ធំ អ្នកភ្នំពេញ ច្រើនណាស់ខ្លះទៅនៅស្រុកអីដើង ចាំមិនអស់ទេ ។

ប៊ុនថន ៖ ចុះអ្នកនោះការងារអី ធ្វើដូចយើងដែរហ្អីមីង?

នឹក ៖ ចាស ធ្វើដូចគ្នា ។

ប៊ុនថន ៖ ចុះដូចអ្នកខ្លះអត់ធ្លាប់ធ្វើដូចថាធ្វើទៅអត់ហើយ ដូចថាធ្វើទៅអត់គ្រប់ផែនការចឹងមាន ទេ?

នឹក ៖ មាន មានអ្នកធ្វើមិនគ្រប់ផែនការចេះតែខំធ្វើតទៅទៀតទៅ ។

ប៊ុនថន ៖ ចុះមានស្លាប់មានអីទេមីង?

នឹក ៖ បើស្លាប់ទៅកន្លែងពេទ្យ មានស្លាប់ខ្លះហើយ ។

ប៊ុនថន ៖ ពេលកំពុងធ្វើការមានអស់កំលាំងឬមួយឈឺ ?

នឹក ៖ អត់មានទេធ្វើការអត់មានស្លាប់ទេបើទៅកន្លែងពេទ្យបានមានស្លាប់ ។

ប្រុញ ៖ ចុះអ្នកមីងម៉េចបានស្គាល់តាវ៉ាល់?

នឹក ៖ ស្គាល់ ។

ប្រុញ ៖ គាត់ចុះមកញឹកញាប់ទេ?

នឹក ៖ គាត់ចុះមក គាត់មានផ្ទះនៅសង់នៅនឹងកន្លែងអាងត្រពាំងថ្ម នៅក្នុងភូមិ ។

ប្រុញ ៖ ផ្ទះគាត់សព្វថ្ងៃនៅទេមីង?

នឹក ៖ ទេ គាត់អត់មាននៅស្រុកនេះផង គាត់អ្នកនិរតីមិនដឹងមកពីខាងណាផងគេហៅនិរតីៗក៏ ហៅតាមគេ ។

ប៊ុនថន៖ កន្លែងគាត់ធ្វើការមីងហ្អីផ្ទះគាត់ហ្នឹងសាងសង់គាត់នៅស្នាក់នៅធ្វើការ?

នឹក ៖ ផ្ទះហ្នឹងគេនៅណាស ដូចគេមានផ្ទះសំណាក់គេនៅ ។

ប្រុញ ៖ ភាគច្រើនគាត់មកតែម្នាក់ឯងឬក៏មានអ្នកមកជាមួយគាត់ដែរ?

នឹក ៖ មានគ្នាកូនចៅកូនដើងគាត់ពីរបីនាក់ ។

ប្រុញ ៖ អ្នកណាគេកូនចៅគាត់មីងស្គាល់ទេ?

នឹក ៖ ខ្ញុំមិនស្គាល់ទេខ្ញុំស្គាល់តែ តាវ៉ាល់ តាម៉ោង តាសន ។

ប្រុញ ៖ តាម៉ោង ហ្នឹងគាត់មកញឹកញាប់ទេ?

នឹក ៖ យូរៗគាត់ចុះមកម្តង ។

ប្រុញ ៖ ចុះក្រៅពី តាម៉ោង តាវ៉ាល់ តាសន មានអ្នកណាធំជាងគាត់ទៀតទេ?

ង៉ឹក់ : មិនមានទេ ឃើញតែមុខគាត់បីនាក់ហ្នឹង ។

ប៊ុនថនៈ ហើយមានចិនមានអីមកទេមីង?

ង៉ឹក់ : អត់ មិនដែលឃើញមានទេ ។

ឡា យុំ : មកហ្នឹងជិះអីមកឬដើរដែលមកម្តងៗ ?

ង៉ឹក់ : ដឹងគាត់ជិះអីបើឃើញតែគាត់មកដល់រោង ។

ឡា យុំ : ស្លៀកពាក់អី?

ង៉ឹក់ : ស្លៀកពាក់ខ្មៅបង់ករក្រមារ ។

ឡា យុំ : ពាក់ស្បែកជើងកង់ឡានដូចខ្ញុំនេះទេ?

ង៉ឹក់ : ស្បែកជើងកង់ឡាន បង់ករកន្សែង ។

ប៊ុនថនៈ : គាត់មកគ្រាន់តែដើរមើលឬដើរបញ្ជា?

ង៉ឹក់ : ចាំ! មកគាត់ដើរបញ្ជាទៅកន្លែងនេះកន្លែងនោះអ្នកលើកដី ។

ប៊ុនថនៈ បញ្ជាអ្នកណាមីងបញ្ជាអ្នកធ្វើការឬប្រធានកង?

ង៉ឹក់ : គេហៅប្រធានៗ ទៅប្រជុំប្រធានក្រុមប្រធានកង ។

ប៊ុនថនៈ មីងដែលទៅប្រជុំហ្នឹងគេទេ?

ង៉ឹក់ : ទៅប្រជុំហើយ ប្រជុំទាល់តែកងវរៈធំមកបានប្រជុំ ។

ប៊ុនថនៈ កងវរៈហ្នឹងពីណាវិញមីង?

ង៉ឹក់ : អត់ស្គាល់ដែរ ។

ប៊ុនថនៈ អស់ស្គាល់ឈ្មោះទេ?

ង៉ឹក់ : ចាស វាច្រើនណាស់ ច្រើនគ្នា ច្រើនអត្តភាពមិនដឹងមកពីខាងណាខាងនីមកជុំគ្នានៅអាង ត្រពាំងថ្ម ។

ប៊ុនថនៈ : ប្រជុំហ្នឹងគេនិយាយពីរឿងអីទៅមីងពេលប្រជុំម្តង?

ង៉ឹក់ : និយាយតែពីរឿងប្តេជ្ញាឲ្យខិតខំបំពេញ អនុវត្តយើងមិនដែលមានអីទេមានតែប៉ុណ្ណឹង ។

ប្រុញ : អ៊ីចឹងមីងពេលដែល តាវ៉ាល់ ហៅប្រធានកងប្រធានវរៈទៅប្រជុំហើយបានប្រធានកង ប្រធានវរៈហ្នឹងទៅប្រជុំទៀត?

ង៉ឹក់ : ចាស ។

ប្រុញ : មានន័យថា តាវ៉ាល់ គាត់ហៅប្រធានកងប្រធានវរៈមកប្រជុំញឹកញាប់?

ង៉ឹក់ : មានហៅក៏ហៅខ្លះទៅ ។

ប្រុញ ៖ ទាល់តែគាត់មកគេហៅទៅប្រជុំទៅ?

ង៉ែក ៖ ចាស គេហៅតែប្រធានកងប្រធានក្រុមទេ ។

ប៊ុនថន៖ នៅទីនោះដូចមានអ្នកលួចរត់លួចអីចេញពីកងទេ?

ង៉ែក ៖ អត់មានទេ តែលួចរត់គេចាប់បានក៏ទៅបណ្តោយ អត់អ្នកណាហ៊ានទេ ចេះតែតស៊ូទៅ ដូចខ្ញុំដូចអីនេះតស៊ូមិនដែលហ៊ានសុំគេមកផ្ទះផងនៅទាល់តែសម័យវៀតណាមចូលបាន មកឃើញបងប្អូន ។

ប៊ុនថន ៖ ម៉េចបានមីងអត់ហ៊ានសុំ?

ង៉ែក ៖ ខ្លាចគេ ខ្លាចគេមិនហ៊ានសុំគេទេ ។

ឡា យុំ ៖ ពេលប្រជុំម្តងៗយើងស្តាប់មើលខ្លឹមសារអត់មានថាវាទៅមុខទៀតធូរស្រាលការងារ ម្ហូបកើនឡើងឆ្ងាញ់អីអត់ទេ?

ង៉ែក ៖ អត់មានទេ ។

ឡា យុំ៖ អត់មានថាដើរលេងសំរាកអីអត់ទេហ្ន៎ គិតតែធ្វើម៉េចប្តេជ្ញាសំរុកធ្វើ?

ង៉ែក ៖ ចាស គិតតែធ្វើម៉េចសំរុកលើកដីទំនប់ហ្នឹងហើយជីកទំនប់ជីកប្រឡាយ ។

ឡា យុំ ៖ ដូចអត់ចង់ទេប្រជុំហ្នឹងមើលទៅ?

ង៉ែក ៖ ថាអត់ចង់ហើយ តែគេហៅចេះតែទៅ គេដើរឆែកតាមខ្ទមតាមរោងអត់ឲ្យនៅ ដើរឆែកអស់ ។

ឡា យុំ ៖ ដល់ប្រជុំហើយដល់ពេលប្តេជ្ញាអីចឹងទៅ?

ង៉ែក ៖ ចាស ។

ឡា យុំ ៖ ទះដៃទះអីទៅ?

ង៉ែក ៖ ទះដៃ ។

ឡា យុំ ៖ ហើយសំដីសំដៅការនិយាយស្តីរបស់ពួកមេៗហ្នឹងម៉េចទៅ សុភាពរាបសារដឹងចាស់ដឹងទុំឬក៏និយាយមក...?

ង៉ែក ៖ អាខ្លះទៅចេះសុភាពរាបសារ អាខ្លះទៅក៏ចេញមកអំពើហឹង្សាតែម្តង ។

ឡា យុំ ៖ សំឡុតម៉ង?

ង៉ែក ៖ ចាស ចេញមកក៏សំឡុត ។

ឡា យុំ ៖ ហ៊ានមើលមុខគេទេពេលគេនិយាយ?

ង៉ែក ៖ អត់ដែលហ៊ានទេ ពឹតតែឈ្ងោក ។

ឡា យុំ ៖ ម៉េចបានខ្លាច?

ង៉ក់ ៖ ខ្លាចគេមែនទែនមិនដែលហ៊ានងើបមើលមុខហ្អាស ។ រែកដីចេះឃើញតែគេមកពីនេះទៅចុងខាងកើត មិនដែលហ៊ានឈរមើលគេទេ សំរុកយកៗ ។

ប្រុញ ៖ មីង ប្រធានបស់មីងត្រូវប្រធានវរៈហៅទៅប្រជុំដែរ?

ង៉ក់ ៖ ហៅ ។

ប្រុញ ៖ គេហៅទៅប្រជុំចឹងដែរ?

ង៉ក់ ៖ ចាស ។

ប្រុញ ៖ ហើយគេហៅយើងកូនកងទៅប្រជុំដែរ ។

ង៉ក់ ៖ ប៉ះណាគេហៅតែប្រធានៗទៅ ថ្ងៃណាគេហៅទាំងកូនក្រុមកូនចៅទៅប្រជុំទាំងអស់គ្នា ។

ប្រុញ ៖ ចុះដល់ពេលដែលប្រធានកងគេហៅទៅប្រជុំដល់ពេលប្រធានកងគាត់មកវិញគេនិយាយប្រាប់យើងម៉េចដែរ ឲ្យធ្វើការ?

ង៉ក់ ៖ អត់និយាយទេ ។

ប្រុញ ៖ អត់ដែលនិយាយជាមួយយើងទេ?

ង៉ក់ ៖ អត់ដែលនិយាយទេ ដល់ព្រឹកឡើងត្រូវទៅលើកទំនប់ក៏ប្រាប់ឲ្យទៅលើកទំនប់ ។

ប៊ុនថន ៖ អ្នកមីងកុមារនៅធ្វើការនៅនោះច្រើនទេកងកុមារ?

ង៉ក់ ៖ ច្រើនគ្រប់ស្រុកគ្រប់ភូមិអត់ស្គាល់អស់ផង ។

ប៊ុនថន ៖ ប៉ុន្តែមីងឃើញក្មេងៗកុមារណាសច្រើនទេអ្នកមីង?

ង៉ក់ ៖ ច្រើន ។

ប៊ុនថន ៖ ប្រហែលប៉ុន្មាន?

ង៉ក់ ៖ ប្រហែលពីររយនាក់សំបូរខាងអ្នកថ្មីខាងកំពង់ចាម កំពង់ធំ ខាងភ្នំពេញច្រើនមកពីនោះឯង ។

ប៊ុនថន ៖ កុមារភាគច្រើនអាយុពីប៉ុន្មានដល់ប៉ុន្មានមីង?

ង៉ក់ ៖ ហ្អស!មិនសូវអាយច្រើនទេ ច្រើនណាស់ដប់ឆ្នាំ ។

ប៊ុនថន ៖ តែដប់ឆ្នាំនៅតូចទេហើយលើកពីរម៉ែត្រលើកម៉េចហើយមីង?

ង៉ក់ ៖ ខ្លាចគេចេះតែខំឲ្យរួចទៅណាស ។

ប៊ុនថន ៖ ម៉ាថ្ងៃពីរម៉ែត្រឬក៏បួនម៉ែត្រមីង?

ង៉ក់ ៖ ពីរម៉ែត្រម៉ាងៃ បើយប់ឡើងគេឲ្យរែកពីរម៉ែត្រគីបទៀត ។

ប៊ុនថន ៖ ចឹងម៉ាថ្ងៃបួនម៉ែត្រគីប?

ងឹក់ ៖ ចាស ។

ប៊ុនថន ៖ បួនម៉ែត្រគីបច្រើនណាស់មីងគិតថាកុមារមិនអាចធ្វើហើយទេ ។

ងឹក់ ៖ ចា៎! អត់ធ្វើហើយទេ ជំរៅ គេកាប់យកជំរៅកន្លះម៉ែត្រ បណ្ដោយពីរម៉ែត្រគីប ។

ប៊ុនថន ៖ ហើយ ចង់សួរថាអ្នកហ្នឹងមិនហើយចឹងម៉េចវិញមីង កុមារៗហ្នឹងណាសគេអនុគ្រោះឬ យ៉ាងម៉េច?

ងឹក់ ៖ គេអនុគ្រោះឲ្យចាំបង្ហើយព្រឹក ។

ប៊ុនថន ៖ បើសិនជាគេគឹងតែងគេធ្វើម៉េចទៅមីង?

ងឹក់ ៖ គឹងតែងគេឲ្យយើងខំទាល់តែរួច ។

ឡាក យុំ ៖ គេដាក់ឲ្យយើងធ្វើហ្នឹងធ្វើជាក្រដាសឬថាតែនឹងមាត់អាពេលកំណត់ថាពីរម៉ែត្រគីបពេលថ្ងៃ ពីរម៉ែត្រគីបពេលយប់?

ងឹក់ ៖ អត់មានក្រដាសទេ វាស់ឲ្យតែម្ដង ។

ឡាក យុំ ៖ គេវាស់ម៉េងហ្នឹ?

ងឹក់ ៖ ចាស ចុះម៉ាក្រុមៗគេវាស់តាមក្រុម ។

ឡាក យុំ ៖ អត់មានអ្នកណាគេភ្លេចទេ?

ងឹក់ ៖ អត់មានភ្លេចទេ ។

ឡាក យុំ ៖ ទេ គិតមើលមកសព្វថ្ងៃបើចាស់ៗពីរម៉ែត្រគីប?

ងឹក់ ៖ លើកអត់រួចទេ ។

ឡាក យុំ ៖ កាលនោះលើករួច?

ងឹក់ ៖ តែទៅប្រជុំទៅអីខ្ញុំដូចរាង ខ្ញុំរាងសម័យកាលនោះទៅប្រជុំយូរៗពេក ។

ឡាក យុំ ៖ និយាយតាមត្រង់ទៅមានដែលសំពះចបដែរអត់ ព្រោះមានអ្នកខ្លះពេលយួនចូលមកដាក់ ចបជំរៀបសំពះខ្លាចចប?

ងឹក់ ៖ អត់ដែលមានទេ ។

ឡាក យុំ ៖ ចបកាលនោះសុទ្ធតែមុតៗអត់មានដូចឥឡូវសុទ្ធតែច្រេះទេ ។

ប្រុញ ៖ មីងនិយាយថាអ្នកធ្វើការអត់ទាន់ហើយគេអត់ឲ្យជួយទៀត?

ងឹក់ ៖ អត់ឲ្យជួយទេ ។

ប្រុញ ៖ ម៉េចបានគេអត់ឲ្យជួយ?

នីក់ ៖ អត់ឲ្យជួយទេបស់អ្នកណាបស់អ្នកនោះ ។

ប្រុញ ៖ ហេតុអីបានគេអត់ឲ្យយើងជួយ?

នីក់ ៖ គេមិនឲ្យយើងជួយថាយើងពឹងផ្អែកកំលាំងគេ គេមិនឲ្យយើងជួយ ។

ប៊ុនថន ៖ កាចទេមីងប្រធានក្រុមបស់មីង?

នីក់ ៖ មានកាចខ្លះស្លូតខ្លះ ។ ខ្លះក៏គេនឹកឃើញខ្លះគេស្លូតខ្លះគេកាច ។

ប៊ុនថន ៖ ប្រធានក្រុមក្មេងដូចមីងដែរហ្អីក៏ម៉េច?

នីក់ ៖ ក្មេងៗ ។

ឡា យុំ ៖ មានដែលឃើញអ្នកណាគេហៅទៅការទៅអីមានទេ?

នីក់ ៖ គេទៅការអីខ្ញុំមិនដែលបានឃើញទេ ។

ឡា យុំ ៖ ប៉ុន្តែពួដែរពួគេការអី?

នីក់ ៖ ពួគេបើកវគ្គនៅត្រពាំងថ្មហ្នឹងឯងតែគេមិនដែលឲ្យខ្ញុំកុមារៗទៅ ។

ឡា យុំ ៖ គេការហ្នឹងគេហៅបើកវគ្គ?

នីក់ ៖ គេហៅបើកវគ្គ គេហៅតែវ័យកណ្តាលទៅ ធូបដើមស្មោ ។

ប្រុញ ៖ មីងពេលនោះព្រមព្រៀងខ្លួនឯងឬគេចាប់យើងការ?

អ្នកជិតខាងៈ បើគេចង់បានគេស្នើយើង ។

ប្រុញ ៖ ចុះមីងយល់ព្រមទេ?

នីក់ ៖ បើមិនព្រមគេយកយើងទៅវៃចោល ។

ប្រុញ ៖ ហើយគេមានគំរាមយើងទេ?

អ្នកជិតខាងៈ មាន បើយើងការរួចហើយគេដើរឈ្លប... ។

ឡា យុំ ៖ ខ្លាចយើងមិនចុះដំណេក?

នីក់ ៖ ចាស ។

អ្នកជិតខាងៈ គេលបមើលយើង ។

ប៊ុនថន ៖ អ្នកមីងនៅធ្វើនៅត្រពាំងថ្មបានប៉ុន្មានខែ?

នីក់ ៖ នៅយូរ យូរទាល់តែយក្សណាមចូលបានខ្ញុំចេញមក ។

ប៊ុនថន ៖ ចុះមីងថាក្រោយមកគេប្តូរឲ្យមកខាងគួរស្រូវ?

នីក់ ៖ នៅនោះឯងនៅត្រពាំងថ្ម ។

ប៊ុនថន ៖ បាទ!មីងនៅកន្លដដែលទេ តែគេដូរការងារ?

ង៉ិក់ ៖ ចាស ។

ប៊ុនថន ៖ ម៉េចបានគេដូរចឹងមីង?

ង៉ិក់ ៖ គេឲ្យកុមារធ្វើការស្រាលៗ ។

ប៊ុនថន ៖ ចឹងដូរទាំងអស់កុមារ?

ង៉ិក់ ៖ ចាស ។

ប៊ុនថន ៖ ប៉ុន្មានដាងពីរយនាក់ហ្នឹងដូរទាំងអស់គ្នា?

ង៉ិក់ ៖ ដូររើសករគួរ ។

ប៊ុនថន ៖ រើសហ្នឹងមានកំណត់ម៉ាថ្ងៃរើសបានប៉ុន្មាន?

ង៉ិក់ ៖ រើសដាក់បាវ ច្រកបាវម៉ាថ្ងៃឲ្យបានប្រាំបាវ ។

ប៊ុនថន ៖ ម៉ាថ្ងៃឲ្យបានប្រាំបាវ?

ង៉ិក់ ៖ ចាស ម៉ាក្រុមដប់នាក់រើសឲ្យបានប្រាំបាវ ។

ប៊ុនថន ៖ ដប់នាក់បានប្រាំបាវ?

ង៉ិក់ ៖ បានប្រាំបាវ ។

ប៊ុនថន ៖ រើសបានទេមីង?

ង៉ិក់ ៖ ជួនកាលក៏បានជួនកាលក៏អត់ ។

ប៊ុនថន ៖ រើសយកទៅណាវិញមីង?

ង៉ិក់ ៖ មិនដឹងគេដឹកទៅខាងណា ។

ប៊ុនថន ៖ យកមកដាក់កង?

ង៉ិក់ ៖ អត់ឃើញយកមកដាក់នៅកងទេ មិនដឹងយកទៅខាងណា ។

ប៊ុនថន ៖ ចឹងកាលនៅខាងគួរស្រូវហ្នឹងមីងដូចថាការងារពិបាកជាងមុនឬយ៉ាងម៉េច?

ង៉ិក់ ៖ អត់សូវពិបាកទេរើសករគួរ ។

ប៊ុនថន ៖ ហើយរបបយ៉ាងម៉េចដែរ?

ង៉ិក់ ៖ របបធម្មតាម៉ាចានៗ ។

ប៊ុនថន ៖ ហើយស្នាក់នៅមីងស្នាក់នៅ...?

ង៉ិក់ ៖ ត្រពាំងថ្ម ។

ប៊ុនថន ៖ ត្រពាំងថ្មដដែលទេ ។

ង៉ិក់ ៖ ចាស ។

ប៊ុនថន : ហើយមីងនៅនោះរហូតដល់វៀតណាមចូលមក?

ងីក់ : នៅទាល់តែវៀតណាមចូល ។

ប៊ុនថន : វៀតណាមចូលមកមីងទៅនៅឯណា?

ងីក់ : វៀតណាមចូលមកដល់ព្រៃមាន់ខ្ញុំនាំគ្នាចែកផ្លូវគ្នាចេញមកនេះបណ្តោយ ចែកផ្លូវគ្នាប្រធានៗ នាំគ្នាដឹកបានដឹកឆ្នាំរត់មកខាងដីថៃខាងភ្នំឆ័ត្រភ្នំអីនេះ ។

ប៊ុនថន : ចុះមីងថាឃើញមានអ្នកស៊ីសាច់មនុស្សសាច់អីអាហ្នឹងនៅឯណាវិញ?

ងីក់ : អាហ្នឹងនៅដេកពេទ្យភ្នំកងវ៉ា ។ វាមិនបានឃើញមនុស្សអាររទេតែព្រឹកឡើងពេទ្យមកឆែកមើលដឹងថាខ្មោចមើលទៅវាអស់ ស្អិតជើង ។

ប៊ុនថន : ហួស!ស្លាប់នៅពេទ្យហ្នឹងមីងហ្អី?

ងីក់ : ស្លាប់នៅពេទ្យ ។

ប៊ុនថន : ហើយអ្នកនោះអ្នកជំងឺទេហ្អីមីង?

ងីក់ : អ្នកជំងឺ អ្នកដែលអារយកសាច់ស៊ីក៏អ្នកជំងឺដែរ ។

ប៊ុនថន : អ្នកហ្នឹងអ្នកថ្មីហ្អីមីង?

ងីក់ : អ្នកថ្មី ។

ប៊ុនថន : ចឹងមីងកាលនោះឈឺអីមីង?

ងីក់ : ខ្ញុំគ្រុនក៏ខ្ញុំមិនទាន់បាត់ផងខ្ញុំសុំគេចេញ ខ្ញុំនឹកខ្លាច ទៅធ្វើការ ។

ប៊ុនថន : ទៅដេកច្រើនថ្ងៃទេមីងទៅកងវ៉ាហ្នឹង?

ងីក់ : ទៅដេកបីយប់ ខ្ញុំខ្លាចខ្ញុំស៊ូអត់បាន ។

ប៊ុនថន : ថ្ងៃដែលមីងឃើញហ្នឹងថ្ងៃទីប៉ុន្មានថ្ងៃដំបូងហ្អី?

ងីក់ : មិនបានរាប់ផងមិនដឹងថ្ងៃណា ថ្ងៃទីបី ខ្ញុំដេកបានបីយប់ខ្ញុំសុំពេទ្យមក ។ ដែលចេញហ្នឹងខ្ញុំអត់ទាន់បាត់ទេ ។

ប៊ុនថន : ចុះអ្នកជំងឺហ្នឹងឈឺអីគេអ្នកដែលគេអារសាច់ហ្នឹង?

ងីក់ : មិនដឹងជាឈឺអីឃើញតែស្គមរីងរៃ ។

ប៊ុនថន : អ្នកហ្នឹងមកដេកមុនមីងទៀត?

ងីក់ : ចាស មកដេកមុនខ្ញុំ ដេកៗនឹងដីទៀតក្រាលសំពត់កៅស៊ូដេកនឹងដីសើម ។

ប៊ុនថន : មានរោងមានអីទេមីង?

ងីក់ : មានរោងតែអត់មានគ្រែ ដេកនឹងដី ។

ប៊ុនថន :	ធំទេមីងរោងហ្នឹង? ប៉ុនផ្ទះមីងទេ?

ងិក់ :	ប៉ុន តែវែង គេធ្វើឡើងវែង ។

ប៊ុនថន :	អ្នកជំងឺច្រើនទេមីង?

ងិក់ :	ហ្អស! ច្រើន ។

ប៊ុនថន :	មកពីណាខ្លះមីង?

ងិក់ :	មកពីណាមកពីណីទេ ។

ប៊ុនថន :	ក្មេងហ្អីចាស់មីង?

ងិក់ :	មានយុវជន នារី កុមារច្រើនណាស់កូន ច្រើន ។

ប៊ុនថន :	ភាគច្រើនជាអីគេវិញមីង?

ងិក់ :	ភាគច្រើនឈឺដាច់ពោះបាយ ។

ប៊ុនថន :	ហើយមកចឹងព្យាបាលជាទេ?

ងិក់ :	អត់ដែលឃើញជាខ្លះស្លាប់នឹងពេទ្យនៅនឹងពេទ្យ ។

ប៊ុនថន :	ស្លាប់ច្រើនទេ?

ងិក់ :	ងាប់ច្រើនជាងអារស់សម័យនោះ ។

ប៊ុនថន :	កាលនោះគេហៅពេទ្យអីគេមីងនៅកងវ៉ា? ពេទ្យឃុំ ពេទ្យស្រុកឬពេទ្យអីគេ?

ងិក់ :	មិនដឹងគេហៅពេទ្យអីទេ គេហៅពេទ្យមិនដឹងពេទ្យអី ។

ប៊ុនថន :	ចុះពីណាអ្នកប្រធានពេទ្យហ្នឹង?

ងិក់ :	អត់ស្គាល់ផង ឃើញតែមុខពេទ្យគេចុះមើលអ្នកជំងឺ ។

ប៊ុនថន :	គាត់អ្នកស្រុកណាដែរ?

ងិក់ :	មិនដឹងអ្នកស្រុកណាមិនដែលសួរនាំផងឮតែពេទ្យក៏ដេកពេទ្យ ។

ប្រុញ :	អ្នកមីងស្គាល់អ្នកដែលអារសាច់ហ្នឹងហូបទេ?

ងិក់ :	អត់ស្គាល់ទេ ។

ប្រុញ :	អ្នកដែលត្រូវគេអារសាច់?

ងិក់ :	អត់ស្គាល់ផង ។

ប៊ុនថន :	តែដឹងថាអ្នកថ្មី?

ងិក់ :	ចាស អ្នកថ្មីតែមិនដែលស្គាល់ទេ ដេកជិតគ្នា ។

ប្រុញ :	ខាងនោះគេបញ្ជូនមកពីខាងណាវិញមីង?

ងឹក់ ៖ អត់ដឹងគេមកពីខាងណាទេច្រើនណាស់បើដេកជុំគ្នានៅកងរ៉ានេះនៅទីងដើងភ្នំ ។

ប្រុញ ៖ ស្លាប់ហើយៗ?

ងឹក់ ៖ បែបស្លាប់ហើយ ។

ប្រុញ ៖ ស្លាប់បានប្រហែលប៉ុន្មានថ្ងៃហើយ?

ងឹក់ ៖ ស្លាប់ដែលគេអារនោះ?

ប្រុញ ៖ បាទ!

ងឹក់ ៖ ម៉ាយប់ ។

ប្រុញ ៖ គាត់ស្លាប់ហើយយប់ឡើងគេអារ?

ងឹក់ ៖ អារថ្ងៃនោះហើយ ។

ប៊ុនថន ៖ អាកន្លែងណាវិញមីង?

ងឹក់ ៖ អាហ្នឹងភ្ជាត់ដើង ។

ប៊ុនថន ៖ កំភួនដើងនេះ?

ងឹក់ ៖ ចាស កំភួនដើង ខ្ញុំដេកជិតគេខ្ញុំខ្លាចសុំពេទ្យចេញ ។

ប៊ុនថន ៖ នៅជាប់មីងម៉ង?

ងឹក់ ៖ ជិតគ្នា ដេកជិតគ្នា ។

ប្រុញ ៖ ហ្នឹងសុទ្ធតែអ្នកជំងឺដូចគ្នាហ្អីមីង?

ងឹក់ ៖ អ្នកជំងឺដូចគ្នា ។

ប៊ុនថន ៖ មីងឃើញទេដែលថានៅជិតគ្នាហ្នឹង?

ងឹក់ ៖ អត់ឃើញគេអារទេ? អត់ឃើញទេ ខ្ញុំដេកលក់ស្រាប់តែក្រោកព្រឹកឡើងគេមកឆែកមើល គេមកមើលអ្នកង៉ាប់ហ្នឹង ។

ប៊ុនថន ៖ មកមើលចឹងគេបើកមើលមីងឃើញដែរ?

ងឹក់ ៖ ចាស ឃើញ ។

ប៊ុនថន ៖ ឃើញកន្លែងគេអារហ្នឹង?

ងឹក់ ៖ ឃើញ ។

ឡា យុំ ៖ អស់ម្នាងទេ?

ងឹក់ ៖ អស់ម្នាង ។

ប្រុញ ៖ ពេលហ្នឹងមីងអត់ទាន់មកនៅត្រពាំងថ្មអីណាហ្អីមីង?

នឹក់ : ខ្ញុំនៅអីណោះរួចបានគេជម្លៀសមកណេះ ។

ឡា យ៉ុ : ពេទ្យហ្នឹងនៅឯណាដែលគាត់និយាយមិញហ្នឹង?

នឹក់ : អត់ស្គាល់ផង ។

ប៊ុនថន : កង់វ៉ា នៅកង់វ៉ា ។

នឹក់ : នៅដើងភ្នំកង់វ៉ា ខ្ញុំមិនដែលស្គាល់គេផង ។

ប៊ុនថន : បាទ! ហើយមីងគេអារក្បាលគេយកចេញក្បាលហ្អី?

នឹក់ : ចាស គេយកទៅកប់ចោលក្បាលគេអត់ទុកទេ ។

ប៊ុនថន : ចុះមីងគេមានសួរមានអីទេមីងនៅជិតហ្នឹង?

នឹក់ : ទេ អត់សួរផង អត់សួរ ខ្មោចងាប់គេយកទៅកប់ ។

ឡា យ៉ុ : ស្លាប់ដោយឈឺទេ?

នឹក់ : ចាំ! ឈឺដាច់ពោះ ឃើញតែសមស្រាប់តែទៅដេកពេទ្យបណ្តោយ ។

ប៊ុនថន : ស្រីឬប្រុសមីង?

នឹក់ : ប្រុស ។

ប៊ុនថន : ចាស់ ឬក្មេង?

នឹក់ : យុវជន ។

ប៊ុនថន : ចុះអត់មានស្លាប់ អារអីចឹងគេអត់មានស្រាវជ្រាវរកអ្នកអារទេ?

នឹក់ : អត់ តែខ្មោចងាប់ហើយយកខ្មោចទៅកប់បណ្តោយ សែងយកទៅកប់អត់ស្រាវជ្រាវអីទេ ។

ប៊ុនថន : ចុះមីងថាឃើញអ្នកដែលអារនោះ?

នឹក់ : រកឃើញគេយកទៅសំលាប់ចោល ។

ប៊ុនថន : រកឃើញដែរមីង?

នឹក់ : ឃើញ ។

ប៊ុនថន : ពីណាគេវិញ?

នឹក់ : អ្នកនៅកន្លែងនោះឯង មិនដឹងចេញមកពីណាផង ។

ប៊ុនថន : គេយកទៅហូបហ្អី?

នឹក់ : ចាំ! គេយកទៅហូប

ឡា យ៉ុ : យកទៅអាំងឬយកធ្វើម៉េច?

ងឹក់ ៖ យកទៅអាំង ។

ប៊ុនថន ៖ អ្នកអារហ្នឹងអ្នកជំងឺដែរឬយ៉ាងម៉េច?

ងឹក់ ៖ អ្នកជំងឺដូចគ្នា អត់ឃ្លានទៅអារបណ្តោយ ។

ប៊ុនថន ៖ មានចាំឈ្មោះទេ?

ងឹក់ ៖ អត់ស្គាល់ទេ ។

ប៊ុនថន ៖ ប៉ុនអ្នកមកពីណាវិញអ្នកអារសាច់?

ងឹក់ ៖ មានមកពីណាទេអ្នកថ្មី សំបូរតែអ្នកថ្មី ។

ប្រុញ ៖ អ្នកមីងសុំសួរទាក់ទងនឹងមីងស្គាល់ឈ្មោះ សយ ឈ្មោះមោង ហើយឈ្មោះវ៉ាល់ ។ មីងដឹងថាមានអ្នកផ្សេងទៀតស្គាល់គាត់ទេ?

ងឹក់ ៖ ខ្ញុំមិនដែលស្គាល់ផង ។

ប្រុញ ៖ ចុះដែលឃើញគាត់ផ្ទាល់ទេ តាវ៉ាល់?

ងឹក់ ៖ តាវ៉ាល់ ហ្នឹង?

ប្រុញ ៖ បាទ!

ងឹក់ ៖ តាវ៉ាល់ ឃើញផ្ទាល់ ។

ប្រុញ ៖ បានទៅជិតគាត់ដែរហ្អី?

ងឹក់ ៖ ឃើញរូបគាត់ផ្ទាល់ ។

ប្រុញ ៖ ពេលហ្នឹងគាត់មកក្នុងអំឡុងពេលចាប់ផ្តើមធ្វើទំនប់ភ្លាមហ្អីក៏គេធ្វើយូរហើយ?

ងឹក់ ៖ គាត់ចាប់ផ្តើមហើយ គាត់ធ្វើប្រធានគេ ប្រធានធំគេ ។

ប្រុញ ៖ ហើយមានដែលគេនិយាយថាហេតុអីបានធ្វើទំនប់ហ្នឹងទេ?

ងឹក់ ៖ អត់ដែលឮនិយាយផង ។

ប្រុញ ៖ អត់ដែលឮនិយាយទេ?

ងឹក់ ៖ គាត់នោះមើលតែគាត់ងាប់នោះពួកគ្នាគាត់ហ្នឹងយកទៅសំលាប់ចោល ។

ប្រុញ ៖ អ្នកគ្នាគាត់យកគាត់ទៅសំលាប់ចោល?

ងឹក់ ៖ ចាស ។

ប្រុញ ៖ ពីណាគេអ្នកយកទៅសំលាប់ចោល?

ងឹក់ ៖ ដឹងបើគេយកទៅគេមិនប្រាប់ ។

ប្រុញ ៖ គាត់ខុសអីគេបានគេយកគាត់ទៅសំលាប់ចោល?

ង៉ក់ ៖ មិនដឹងខុសអីសម័យកាលនោះពិបាកខុសណាស់ ។ យកគាត់ទៅសំលាប់នៅព្រៃកូនខ្វែង អានេះបែបក្បត់គ្នាបន្តិចឹង ។

ប្រុញ ៖ តាមោង តាសយ ហ្នឹងគេយកទៅសំលាប់ចោលនៅព្រៃកូនខ្វែង?

ង៉ក់ ៖ បើ តាវ៉ាល់ សំលាប់នៅព្រៃកូនខ្វែង ។

ឡា យុំ ៖ តាមោង ឬតាម៉ោង?

ង៉ក់ ៖ តាម៉ោង ។

ប្រុញ ៖ តាមោង?

ង៉ក់ ៖ តាម៉ោង ។

ប្រុញ ៖ មោងហ្អី?

ង៉ក់ ៖ តាម៉ោង មួយទៀតឈ្មោះ តាសន ។

ប្រុញ ៖ តាសន ហ្នឹងសំលាប់ជាមួយ តាវ៉ាល់ តាម៉ោងហ្នឹងដែរហ្អី?

ង៉ក់ ៖ តាសន មិនដឹងគាត់ស្លាប់អីណា ដឹងតែ តាវ៉ាល់ គេយកទៅវៃចោល ។

ប្រុញ ៖ ភូមិកូនខ្វែង?

ង៉ក់ ៖ ចាស ។

ប្រុញ ៖ ភូមិកូនខ្វែងកាលនោះពីណាអ្នកកាន់កាប់?

ង៉ក់ ៖ ខ្ញុំមិនដែលបានទៅដល់ហ្នឹងផង ខ្ញុំនៅតែអាត្រពាំងថ្មមិនដែលបានទៅដល់នោះទេ គេច្រើនតែវ៉ៃយកណ្តាលគេបញ្ជូនទៅនោះ ។

ឡា យុំ ៖ ចុះដល់ខែវស្សាអាងហ្នឹងម៉េចទៅទឹកចូលពេញលើកម៉េចកើត?

ង៉ក់ ៖ ខែវស្សាគេកាប់ គេឲ្យលើកកូនប្រឡាយកូនភ្លឺតូចៗ វាមិនខុះការងារឲ្យយើងធ្វើទេ ។

ឡា យុំ ៖ អត់មានទំនេរអង្គុយលេងអីទេ?

ង៉ក់ ៖ គ្មានទំនេរទេ ។

ឡា យុំ៖ អត់មានអ្នកណាអត់ការងារធ្វើទេ?

ង៉ក់ ៖ មានទាំងអស់ ម៉ាឆ្នាំបីដងក៏យើងមិនបានហូបឆ្អែត ។

ឡា យុំ៖ ឃើញដែរឃើញគេច្រូតបានស្រូវបានអីមករួចបាត់ស្រូវមានឆ្ងល់ដែរ?

ង៉ក់ ៖ ស្រូវមិនដឹងដឹកទៅខាងណាអត់ដែលឃើញ ។

ឡា យុំ៖ ឃើញបាត់អស់ហ្អី?

ង៉ក់ ៖ ចាស ប្រោករួចក៏បាត់ៗមិនដឹងដឹកទៅខាងណា មិនដឹងដឹកបញ្ចូលទៅខាងណា ។

ឡា យ៉ុះ ឡានមកដឹកហ្អី

ងឹក់ ៖ អត់ដឹងមិនដែលឃើញឡានមកផង មិនដឹងយកទៅតាមណាខ្លាចតែគេដឹកយប់

ប្រុញ ៖ មីងពេលនៅត្រពាំងថ្មពាក់ព័ន្ធនឹងទឹក ហូបបានគ្រប់គ្រាន់ មុជបានគ្រប់គ្រាន់ទេ?

ងឹក់ ៖ ហូបទឹក?

ប្រុញ ៖ បាទ!

ងឹក់ ៖ ហូបគ្រប់គ្រាន់ទឹក ទឹកស្រះគេមាននៅហ្នឹង ។

ប្រុញ ៖ នៅត្រពាំងថ្មមានស្រះដែរ?

ងឹក់ ៖ មាន កន្លែងវត្តគេ ។

ប្រុញ ៖ មានទឹកមុជអីគ្រប់គ្រាន់ដែរ?

ងឹក់ ៖ មាន ។

ឡា យ៉ុះ រឿងហ្នឹងចប់យូរហើយប៉ុន្តែដែលឮគេនិយាយពីរឿងកាត់ទោសអាមេធំៗ ធំជាង តាវ៉ាល់ ច្រើនដងណាស់?

ងឹក់ ៖ អត់ដែលឮទេខ្ញុំឃើញតែមុខ តាវ៉ាល់ តាសន តាម៉ោង ។

ឡា យ៉ុះ ឥឡូវនេះដែលឮគេកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ងឹក់ ៖ អត់ដែលឮសោះ ។

ឡា យ៉ុះ អត់ដែលឮសោះម៉េង?

ងឹក់ ៖ អត់ដែលឮ ។

ឡា យ៉ុះ ដែលស្តាប់វិទ្យុអី អត់ដែលឮទេផ្ទះជិតៗនេះអី?

ងឹក់ ៖ បំភ្លេចចោលអស់ហើយ ។

ឡា យ៉ុះ ហើយយប់ឡើងទៅមើលទូរទស្សន៍ផ្ទះណា?

ងឹក់ ៖ មើលស៊ីឌីផ្ទះក្មួយ ដាក់ឌីស ។

ឡា យ៉ុះ អត់ដែលមើលពត៌មានអីទេ?

ងឹក់ ៖ អត់ ។

ឡា យ៉ុះ វិទ្យុអីដែលស្តាប់ទេ?

ងឹក់ ៖ អត់មានផង អត់មានវិទ្យុ ។

ឡា យ៉ុះ ចុះដែលគិតថាអ្នកដែលធ្វើអាក្រក់ៗកាលនោះ ក្នុងចិត្តយើងដែលគិតថាធ្វើអាក្រក់គួរតែ កាត់ទោសកាត់អីទេ?

**ង៉ឹក ៖** កាត់ទោស កាត់គេយ៉ាងម៉េចបើគេទៅឆ្ងាយអស់ហើយ ។

**ឡា យុំៈ** ទេ និយាយអ្នកនៅរស់ ងាប់គេអត់កាត់ទេ អ្នករស់ហ្នឹង?

**ង៉ឹក ៖** មិនដឹងអ្នកណានៅរស់បើគេទៅអស់ហើយ ។

**ឡា យុំៈ** អត់ទេធំ ខ្ញុំអត់និយាយត្រឹមហ្នឹងទេ អាត្រឹមហ្នឹងបើនៅក៏គេអត់កាត់ដែរ ជនដៃដល់គេ ហៅពេជឃាតណាសពួកហ្នឹងណាសគ្នាធ្វើតាមគេទេ បើគេសំលាប់ៗអាលើណោះចឹងគេ កាត់ទោសអាលើធំៗ ។

**ង៉ឹក ៖** អត់ដែលព្រុជង ។

**ឡា យុំៈ** ហើយមីងគិតថាគួរកាត់ទោសដែរអត់? យល់អត់ដល់ហ្អី? ចឹងចង់បានអីទៅឥឡូវចប់ អស់ហើយ កាលនោះនឹកឃើញអនុសាវរីយ៍ដូរចត់ចង់បានអីដែរអត់? ចង់បានអីពីអា កាលនោះ ចង់ឲ្យគេសង ចង់ឲ្យគេសុំទោស ។

**ង៉ឹក ៖** មិនចង់បានអីផង ។

**ឡា យុំៈ** ឬក៏ចង់ឲ្យគេសុំទោសក៏បានដែរបើមិនចង់បានអីធំដុំចឹងណាស!

**ង៉ឹក ៖** ចាស ។

**ឡា យុំៈ** មនុស្សយើងចឹងហើយអាខ្លះគេរៃបែកក្បាលបែកឈាម ហើយថាខ្ញុំសុំទោសខ្ញុំរៃមែន ប៉ុណ្ណឹងអស់ចិត្តហើយ ។ ពេលដែលពួកខ្ញុំសួរគាត់ពីមុនរហូតមកដល់ពេលនេះអារម្មណ៍ មាននឹកឃើញឡើងវិញទេនៅពេលយប់ចឹង?

**ង៉ឹក ៖** អត់មានទេ អារម្មណ៍ រូបភាពពីសម័យនោះអត់មានទេ ។

**ឡា យុំៈ** ភ្លេចអស់ហើយ បំភ្លេចចោល ។

**ង៉ឹក ៖** ចាស បំភ្លេចចោល ។

**ឡា យុំៈ** វាភ្លេចខ្លួនវាឬដោយសារយើងខំបំភ្លេច?

**ង៉ឹក ៖** ខំបំភ្លេចខ្លួនឯង ។

**ឡា យុំៈ** អត់មានថ្ងៃណានឹកឃើញថា ហ្អេស! គិចមានទៀតអីអត់ទេហ្ន៎?

**ង៉ឹក ៖** អត់មានទេ ។

**ឡា យុំៈ** មានដែលអុជធូបដើមស្មោអីទៀតទេ?

**ង៉ឹក ៖** មិនដែលបានអុជអាដើមស្មោហ្នឹងទេ មានតែគេអ្នកបើកវត្តបានអុជដើមស្មោ ។

**ឡា យុំៈ** ម៉េចបានគេឲ្យអុជធ្វើអីបើអត់មានធូបផង ។

**ង៉ឹក ៖** អុជធូប ។

ឡា យុំៈ អ្នកណាអ្នកអុជ?

ង៉ិក់ ៈ គេអ្នកភ្ជាប់ពាក្យហ្នឹងណាស ស្មើគ្នាគេអុជធូបបណ្តោយមិនដឹងថាវាឲ្យអុជយ៉ាងម៉េចហ្អាស ។

ឡា យុំៈ ប៉ុននៅចាំពាក្យបើកវគ្គហ្នឹងជំនួសការហើយហ្ន៎?

ង៉ិក់ ៈ ចាស ។

ឡា យុំៈ ចុះប្រជុំគេហៅប្រជុំមទេ? មេទ្ទឹងអីដែលឮទេ?

ង៉ិក់ ៈ ឮ បើកអន្តកេមេទ្ទឹង ។

ឡា យុំៈ ប៉ុនអាមួយណាក៏អត់មានអារម្មណ៍យើងសប្បាយដែរហ្ន៎?

ង៉ិក់ ៈ អត់មានទេ ។

ឡា យុំៈ តឹងតែងដូចគ្នា?

ង៉ិក់ ៈ ចាស ចេញមួយណាមកក៏តឹងៗ ។

ប៊ុនថន ៈ មីងនៅនេះមានស្គាល់ យាយថែមទេ?

ង៉ិក់ ៈ យាយថែម?

ប៊ុនថន ៈ បាទ!

ង៉ិក់ ៈ មិនដែលស្គាល់ទេ ។

ប៊ុនថន ៈ ដែលឮឈ្មោះគាត់ទេ?

ង៉ិក់ ៈ ឮតែគេថាយាយថែមៗ តែខ្ញុំមិនដែលឃើញរូបទេ ឮគេហៅដែរតែមិនដែលឃើញរូប ។

ប៊ុនថន ៈ ចុះស្រុកខាងព្រះនេត្រព្រះអ្នកណាគណៈស្រុកមីង?

ង៉ិក់ ៈ អត់ស្គាល់ទេ តាសន ហ្នឹងឯង ។

ប៊ុនថន ៈ ចុះមីងសព្វថ្ងៃធ្វើអីដែរមីង?

ង៉ិក់ ៈ ខ្ញុំឈឺខ្ញុំមិនដែលរកអីហ្នឹងគេដង ។

ប៊ុនថន ៈ ចុះគ្រួសារមីង?

ង៉ិក់ ៈ នៅនេះ ។

ប៊ុនថន ៈ គាត់នៅស្រុកនេះដែរហ្អី?

ង៉ិក់ ៈ ចាស នៅស្រុកនេះ ។

ប៊ុនថន ៈ ហើយកូនប៉ុន្មាននាក់ដែរមីង?

ង៉ិក់ ៈ ខ្ញុំកូនប្រាំ ។

ប៊ុនថន ៖	មានគ្រួសារអស់ហើយ?

ងឹក់ ៖	មាន មានមួយបែកនៅផ្សេងហើយ ។

ប៊ុនថន ៖	បាទ ចុះមានបានទៅរៀនអីដែរ?

ងឹក់ ៖	រៀន ។

ប៊ុនថន ៖	បានរៀនទាំងប្អូននាក់ហ្អី?

ងឹក់ ៖	ស្រីមួយនោះមិនបានរៀនទេ រៀនក៏ខ្ញុំអត់រៀនថ្នាក់ទីប្រាំទីប្រាំមួយកូនចង់ឈប់ មិនបានរៀនដល់ថ្នាក់ខ្ពស់នឹងគេទេ ។

ប៊ុនថន ៖	ចឹងមីងមានអីចង់បន្ថែមទេ?

ងឹក់ ៖	អត់មានទេ ។

ប៊ុនថន ៖	ចង់បន្ថែមកន្លែងណាមីងចាំទេ?

ងឹក់ ៖	អត់ទេ ។

ប៊ុនថន ៖	ចឹងខ្ញុំអគុណមីង ។

ងឹក់ ៖	ចាស ។

«ចប់»